ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ០២៤/២០ ក.ប/ស.ជ.ណ.ម.ហ

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមរំលឹកម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុនទាំងអស់ ស្ថិតនៅក្រោមដែនអនុវត្តន៍នៃច្បាប់ស្តីពីការងារ ដែលមានប្រើប្រាស់កម្មករនិយោជិតជាជនបរទេស និងជនបរទេសដែលប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជាជ្រាបថា ជនបរទេសមួយចំនួននៅមិនទាន់បានមកបំពេញកាតព្វកិច្ចស្នើសុំធ្វើ ឬពន្យារបណ្ណ/សៀវភៅការងារជនបរទេស សម្រាប់ឆ្នាំ២០២០នៅឡើយ។

សូម ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុនទាំងអស់ និងជនបរទេស ត្រូវស្នើសុំធ្វើ ឬពន្យារបណ្ណ/សៀវភៅការងារជនបរទេសសម្រាប់ឆ្នាំ២០២០ តាមរយៈគេហទំព័រ www.fwcms.mlvt.gov.kh ។ ករណីម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុនទាំងអស់ និងជនបរទេសដែលប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា មិនមានបណ្ណ/សៀវភៅការងារជនបរទេស ក្រុមអធិការកិច្ចហត្ថពលកម្មបរទេស នឹងផាកពិន័យតាមច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថាម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុនទាំងអស់ ដែលមានប្រើប្រាស់កម្មករនិយោជិតជាជនបរទេស និងជនបរទេសដែលប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ សុក្រ ៣រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញថ្ងៃទី ៧ ខែសីហា ឆ្នាំ២០២០

រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
-សមាគមនិយោជក "ដើម្បីជ្រាប និងអនុវត្ត"
-ឯកសារ-កាលប្បវត្តិ